# ព័ត៌មានស្តីពីការផ្តល់ប្រាក់ឧបត្ថម្ភពិសេស សម្រាប់ COVID-19

ព័ត៌មានខាងក្រោមនេះក៏មានជាភាសាអង់គ្លេស (ហើយនឹងភាសាផ្សេងៗទៀត) នៅវេបសាយរបស់ក្រុង ហ៊ីហ្គាស៊ីហ៊ីរ៉ូស៊ីម៉ា (Higashihiroshima) តាមរយៈអាសយដ្ឋានខាងក្រោម៖

ភាសាបរទេស

URL https://www.city.higashihiroshima.lg.jp/soshiki/seisakukikaku/1/2/1/covid19/24205.html

○គោលបំណងនៃការផ្តល់ប្រាក់ឧបត្ថម្ភពិសេសសម្រាប់ COVID-19

អាស្រ័យដោយមានការរីករាលដាលនៃមេរោគ COVID-19 (មេរោគកូរ៉ូណាថ្មី) និងការប្រកាសដាក់រដ្ឋក្នុងគ្រាអាសន្ន ប្រជាជនទាំងអស់ត្រូវរួបរួមសាមគ្គីគ្នាដើម្បីប្រយុទ្ធប្រឆាំងជាមួយសត្រូវដែលគ្មានរូបរាង និងឆ្លងអោយផុតវិបត្តិនេះ។ ដោយការកោតសរសើរ ការដឹងគុណ និងការគោរពចំពោះប្រជាជនទូទាំងប្រទេសដែលកំពុងខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការប្រយុទ្ធប្រឆាំងដោះស្រាយវិបត្តិ រួមទាំងអ្នកកំពុងបំពេញការងារផ្នែកវេជ្ជសាស្ត្រ គម្រោងនេះមានគោលបំណងដើម្បីផ្តល់ការគាំទ្របន្ទាន់ និងសមស្របសម្រាប់គាំទ្រហិរញ្ញវត្ថុគ្រួសារតាមរយៈការដាក់ពាក្យស្នើសុំ។

○ លក្ខណៈវិនិច្ឆ័យ ដើម្បីទទួលបានប្រាក់ឧបត្ថម្ភពិសេសសម្រាប់ COVID-19

អ្នកទាំងឡាយណាដែលបានចុះបញ្ជីអាសយដ្ឋាននៅក្រុង Higashihiroshima ត្រឹមថ្ងៃទី២៧ ខែមេសា ឆ្នាំ ២០២០ (អ្នកទាំងឡាយណាដែលមាន វិញ្ញាបនបត្របញ្ជាក់ការស្នាក់នៅ)។

ប្រជាជនដែលមិនមែនជាជនជាតិជប៉ុន ដែលបានចុះបញ្ជីអាសយដ្ឋាន គឺអាចទទួលបានដូចគ្នា។ ប៉ុន្តែអ្នកស្នាក់នៅរយៈពេលខ្លី(បណ្តោះអាសន្ន) និងអ្នកស្នាក់នៅមិនស្របច្បាប់ ដែលមិនបានចុះបញ្ជីអាសយដ្ឋាន គឺពួកគេ មិនអាចទទួលបានការឧបត្ថម្ភពិសេសនេះទេ។

○ អ្នកដែលអាចដាក់ពាក្យស្នើសុំ ប្រាក់ឧបត្ថម្ភពិសេសសម្រាប់ COVID-19

ពាក្យស្នើសុំប្រាក់ឧបត្ថម្ភពិសេសសម្រាប់ COVID-19 គួរត្រូវបានបំពេញដោយមេគ្រួសារ ហើយថវិកាទាំងនោះនឹងត្រូវប្រគល់ជូនទៅមេគ្រួសារតែម្តង។

○ ចំនួនទឹកប្រាក់ឧបត្ថម្ភពិសេសសម្រាប់ COVID-19

១00,000 យ៉េន (yen) សម្រាប់មនុស្សម្នាក់។

○ វិធីក្នុងការស្នើសុំ ៖ ដើម្បីការពារការឆ្លងរីករាលដាលនៃមេរោគ COVID-19 សូមកុំធ្វើការស្នើសុំដោយផ្ទាល់ នៅបញ្ជរការិយាល័យក្រុង។

1 ការស្នើសុំតាមរយៈប៉ុស្តិ៍ប្រៃសណីយ៍

សូមបំពេញ "ពាក្យស្នើសុំប្រាក់ឧបត្ថម្ភពិសេសសម្រាប់ COVID-19" ដោយមានព័ត៌មានគណនីធនាគារ ស្ថាប័នហិរញ្ញវត្ថុ ដែលប្រាក់ឧបត្ថម្ភពិសេសនឹងត្រូវផ្តល់ជូន ជាដើម។ ផ្ញើពាក្យស្នើសុំនេះត្រលប់មកវិញក្នុងស្រោមសំបុត្របិទជិត។

សូមភ្ជាប់ជាមួយពាក្យស្នើសុំប្រាក់ឧបត្ថម្ភពិសេស នូវឯកសារដូចខាងក្រោម៖

- ឯកសារបញ្ជាក់អត្តសញ្ញាណអ្នកស្នើសុំ៖ ឯកសារថតចម្លង នៃប័ណ្ណបើកបរ ប័ណ្ណធានារ៉ាប់រងសុខភាពជាតិ ប័ណ្ណស្នាក់នៅ...។
- ឯកសារបញ្ជាក់ព័ត៌មានលម្អិតអំពីធនាគារដែលត្រូវទទួលប្រាក់ឧបត្ថម្ភ៖ ឯកសារថតចម្លងនៃសៀវភៅធនាគាររបស់អ្នក ប័ណ្ណធនាគារ (កាត ATM)...។

2 ការស្នើសុំតាម អនឡាញ (online) (សម្រាប់អ្នកមានប័ណ្ណ My number រួមជាមួយកុំព្យូទ័រ រឺទូរស័ព្ទឆ្លាតវៃ)

នៅទំព័រពាក្យស្នើសុំ លើប្រអប់ My number ចូរបំពេញព័ត៌មានលម្អិតរបស់មេគ្រួសារ ចំនួនសមាជិកគ្រួសារ និងព័ត៌មានលម្អិតគណនីធនាគារដែលត្រូវទទួល ហើយភ្ជាប់(upload)ជាមួយឯកសារបញ្ជាក់។

**○ កាលបរិច្ឆេទនៃការទទួលពាក្យ**

**ពាក្យស្នើសុំត្រូវផ្ញើអោយបានត្រឹម ថ្ងៃច័ន្ទ ទី៣១ ខែសីហា ឆ្នាំ២០២០។ ពាក្យស្នើសុំតាមកាលបរិច្ឆេទនេះ គឺអាចទទួលយកបាន។**

សាកសួរព័ត៌មានស្តីពី ប្រាក់ឧបត្ថម្ភពិសេសសម្រាប់ COVID-19៖

ការិយាល័យប្រឆាំងមេរោគកូរ៉ូណា ការិយាល័យក្រុង Higashihiroshima ☎ 082-426-3127

ម៉ោងធ្វើការ៖ ៨:៣០ ដល់ ១៧:១៥ (បិទថ្ងៃសៅរ៍ អាទិត្យ និងថ្ងៃបុណ្យជាតិ)

សូមអានទំព័របន្ទាប់ទៀត

## ទម្រង់បែបបទ មុនទទួលបានការទូទាត់ប្រាក់ឧបត្ថម្ភពិសេសសម្រាប់ COVID-19

[ការស្នើសុំតាមរយៈប៉ុស្តិ៍ប្រៃសណីយ៍] ※សម្រាប់ការស្នើសុំតាមរយៈ online សូមធ្វើតាមការណែនាំនៅលើប្រអប់ My number។

① ក្រោយពីអ្នកទទួលបានព័ត៌មានស្តីពី ការទូទាត់ប្រាក់ឧបត្ថម្ភពិសេសសម្រាប់ COVID-19 សូមអានព័ត៌មាន និងទម្រង់បែបបទការទូទាត់ប្រាក់ឧបត្ថម្ភពិសេសសម្រាប់ COVID-19 ដោយប្រុងប្រយ័ត្ន។

② បំពេញព័ត៌មានចាំបាច់នានាក្នុង "ទម្រង់ស្នើសុំការទូទាត់ប្រាក់ឧបត្ថម្ភពិសេសសម្រាប់ COVID-19" ហើយប្រាកដថាអ្នកមានឯកសារយោងចាំបាច់នានាគ្រប់គ្រាន់។

< ចំនុចដែលគួរកត់សម្គាល់>

☑ 不要
ខ្ញុំមិនចង់ទទួលការទូទាត់ទេ

[2] អ្នកដែលគូស ធីកនៅក្នុងប្រអប់ '☐不要' **នឹងមិនទទួលបានការទូទាត់ប្រាក់ឧបត្ថម្ភពិសេសសម្រាប់ COVID-19 នោះទេ។**

សូមប្រាកដថាអ្នកមិនបានច្រលំ គូស ធីក ក្នុងប្រអប់នេះទេ

[3] សូមជ្រើយក គណនីធនាគារមួយដែលអ្នកប្រើប្រាស់ជាទៀងទាត់ សម្រាប់ធ្វើការទូទាត់។

ប្រសិនបើអ្នកជ្រើសយក គណនីធនាគារដែលអ្នកមិនបានប្រើប្រាស់ជាយូរមក ហើយនោះ វាប្រហែលជាមិនអាចធ្វើការទូទាត់បាននោះទេ។

☑ 水道料金の引落
ធនាគារ សម្រាប់ទូទាត់វិក្កយបត្រទឹក

・ប្រសិនបើអ្នកជ្រើសយកគណនីធនាគារ ដែលបានចុះបញ្ជីជាមួយ ក្រុង Higashihiroshima សូមគូស ធីក នៅក្នុងប្រអប់ដែលសមស្រប ដូចទៅនឹងឧទាហរណ៍នៅខាងស្តាំនេះ។

・អ្នកអាចជ្រើសរើសការទូទាត់ជាសាច់ប្រាក់បាន ក្នុងករណីអ្នកមិនមានគណនីធនាគារ។ ក្រុង Higashihiroshima នឹងធ្វើការសម្រេច ពីពេលវេលាដែលត្រូវប្រគល់សាច់ប្រាក់ជូន។ សូមអញ្ជើញទៅទីតាំងដាក់លាក់ដែលកំណត់ដោយក្រុង (ការិយាល័យក្រុង...) តាមកាលបរិច្ឆេទដែលត្រូវទទួល។

[5] ឯកសារយោងសំខាន់ៗមានដូចខាងក្រោម៖

(ឯកសារបញ្ជាក់អត្តសញ្ញាណអ្នកស្នើសុំ)៖ ឯកសារថតចម្លង នៃប័ណ្ណបើកបរ ប័ណ្ណធានារ៉ាប់រងសុខភាពជាតិ ប័ណ្ណ My number (តែផ្នែកខាងមុខ) ប័ណ្ណស្នាក់នៅ (ទាំងផ្នែកខាងមុន និងផ្នែកខាងខ្នងនៃប័ណ្ណ) លិខិតឆ្លងដែន...។

※ ប្រសិនបើពាក្យស្នើសុំបំពេញដោយអ្នកតំណាង **ឯកសាររបស់អ្នកតំណាង និង ឯកសាររបស់មេគ្រួសារ គឺត្រូវការចាំបាច់**។

(ឯកសារបញ្ជាក់ព័ត៌មានលម្អិតអំពីធនាគារ ដែលត្រូវទទួលប្រាក់ឧបត្ថម្ភ)៖ ឯកសារថតចម្លងនៃសៀវភៅធនាគាររបស់អ្នក(បើកសៀវភៅនៅទំព័រទីមួយ) ប័ណ្ណធនាគារ(កាតATM) រូបអេក្រង់ធនាគារតាមរយៈអ៊ីនធឺណេត(internet banking screen)....(ឯកសារដែលបង្ហាញអំពី ស្ថាប័នហិរញ្ញវត្ថុ ឈ្មោះសាខា លេខគណនី និងឈ្មោះ(katakana)ម្ចាស់គណនី)

③ សូមដាក់ ពាក្យស្នើសុំការទូទាត់ប្រាក់ឧបត្ថម្ភពិសេសសម្រាប់ COVID-19 រួមជាមួយឯកសារយោងចាំបាច់(ថតចម្លង) ទៅក្នុងស្រោមសំបុត្របិទជិត ហើយផ្ញើទៅក្រុង Higashihiroshima។

④ ការទូទាត់ប្រាក់ឧបត្ថម្ភពិសេសសម្រាប់ COVID-19 (នៅក្នុងជំហ៊ាននេះ គឺដូចទៅការស្នើសុំតាមរយៈ online ដែរ) ក្រុង Higashihiroshima នឹងធ្វើការផ្ទៀងផ្ទាត់ឯកសារដែលអ្នកបានផ្តល់ ហើយទូទាត់សាច់ប្រាក់ចូលទៅក្នុងកុងធនាគារ ដែលអ្នកបានផ្តល់។
យើងនឹងធ្វើការទូទាត់អោយលឿនតាមដែលអាចធ្វើទៅបាន។ ប៉ុន្តែដំណើរការនៃការពិនិត្យទូទាត់ អាចប្រើពេលមួយខែ ក្រោយពីបានទទួលពាក្យស្នើសុំរបស់អ្នក។

សូមប្រយ័ត្នចំពោះការឆបោកទាក់ទងនឹងមេរោគកូរ៉ូណា និងការទូទាត់ប្រាក់ឧបត្ថម្ភពិសេសសម្រាប់ COVID-19!

មន្ត្រី រដ្ឋាភិបាលថ្នាក់ក្រុង ឬថ្នាក់ជាតិ... នឹងមិនស្នើសុំឱ្យអ្នកផ្ទេរថ្លៃជើងសារ រឺទិញលុយអេឡិចត្រូនិក ប្រតិបត្តិការម៉ាស៊ីនអេធីអឹម (ធនាគារ ហាងទំនិញនានាជាដើម) ទាក់ទងនឹងការទូទាត់ប្រាក់ឧបត្ថម្ភពិសេសសម្រាប់ COVID-19 នោះទេ។

លើសពីនេះទៅទៀត មន្ត្រីរដ្ឋាភិបាលថ្នាក់ក្រុង ឬថ្នាក់ជាតិ....នឹងមិនសួររកលេខកាតឥណទាន លេខកូដ (PIN )សម្រាប់គណនីធនាគាររបស់អ្នក...នោះទេ។

ប្រសិនបើអ្នកទទួលបានការហៅទូរស័ព្ទណាមួយគួរឱ្យសង្ស័យ សូមទាក់ទងទៅប៉ូលីស។